សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ ដំណោះស្រាយរឿងព្រះវេស្សន្តរត្រង់នគរកណ្ដាល គឺព្រះអង្គចេញទៅបួសជាតាបសឥសីហើយ តែបែរជាយាងមកនគរសោយរាជ្យឲ្យជាប់ជំពាក់ទៅវិញ ។

www.hoksavann.org

ថ្ងៃទី២១ ឧសភា ២០១២



ព្រះវេស្សន្តរបានតាំងព្រះទ័យនេះជានិច្ច មិនថាតែបុត្រភរិយាទ្រព្យសម្បត្តិទេ សូម្បីតែជីវិតក៏ព្រះអង្គតាំងព្រះទ័យលះរួចហើយ ។ ក្រោយពេលដែលសំរេចព្រះទ័យចេញទៅភ្នំគីរីវង្កត តាមសំណូមពររបស់អ្នកស្រីពិរាស្រ្តមក ។ ព្រះវេស្សន្តរបានផ្ញើព្រះនាងមទ្រីនិងបុត្រទាំងពីរចំពោះព្រះបាទស្រីសញ្ជ័យនិងព្រះនាងសុបារសុប្បតី ជាព្រះបិតានិងព្រះមាតា តែព្រះនាងមទ្រីពុំព្រមនៅ សុំទៅតាមបំរើព្រះអង្គ ។ ត្រង់នេះបញ្ជាក់ថា ដំបូងព្រះវេស្សន្តរគ្មានបំណងយកព្រះនាងមត្រីនិងបុត្រទាំងពីរទៅឡើយ តែដោយព្រះនាងអង្វរពេក ទើបព្រះអង្គយល់ព្រមឲ្យព្រះនាងយាងទៅ ។ នៅពេលដែលព្រះអង្គយាងទៅជាមួយនាងមទ្រីនិងបុត្រទាំងពីរ ពួកព្រាហ្មណ៍បានសុំរាជរថនិងសេះដែលទឹមរាជរថនោះ ក៏ព្រះអង្គក៏ដាក់ទានទៀតហើយយាងដោយព្រះបាទទទេ ។ លុះយាងបានឆ្ងាយបន្តិច បានជួបនគរមួយ ឈ្មោះនគរចេតរាស្ត្រ ។ ពួកស្ដេចក្នុងនគរនោះ បានជ្រាបអំពីព្រឹត្តិការណ៍ដែលនាំឲ្យព្រះវេស្សន្តរឃ្លាតចេញពីព្រះនគរមក ។ ស្ដេចចេតរាស្ត្រមានសទ្ធាជ្រះថ្លាបានសុំយាងព្រះអង្គឲ្យសោយរាជ្យនៅនគររបស់ខ្លួន តែព្រះអង្គពុំព្រមទទួល ។ ព្រះអង្គសុំទូលសួរតែផ្លូវទៅកាន់ភ្នំគីរីវង្កតប៉ុណ្ណោះ ។ លុះពេលទៅដល់ភ្នំគីរីវង្កតហើយ ព្រះវេស្សន្តរមានបន្ទូលទៅកាន់នាងមទ្រីថា ចូរនាងទៅអាស្រមមួយផ្សេងជាមួយនឹងបុត្រទាំងពីរ ចំណែកយើងនៅអាស្រមមួយទៀតផ្សេង យើងទាំងពីរបួសជាតាបសឥសីតាំងចិត្តឲ្យបរិសុទ្ធ យប់ព្រលប់បើមានការអ្វី គ្រាន់តែគោះទ្វារនិយាយពីក្រៅបានហើយ ។ ត្រង់នេះហើយ បានជាព្រះនាងមទ្រីយោសប្ដិឃើញថា មានព្រាហ្មណ៍ចាស់ម្នាក់ យកកាំបិតមកពុះទ្រូងរូងយកថ្លើមទាំងពីររបស់ព្រះនាងបាត់ទៅ ។ នាងភ្ញាក់ឡើងភ័យណាស់ ប្រញាប់ប្រញាល់ទៅអាស្រមព្រះវេស្សន្តរដើម្បីសុំកាត់សប្ដិ ។ ពេលនោះព្រះវេ-ស្សន្តរពុំព្រមបើកទ្វារឲ្យឡើយ ឲ្យព្រះនាងមានសវនីយ៍រឿងយោសប្ដិនោះពីខាងក្រៅទ្វារ ។ ត្រង់នេះបញ្ជាក់ថា ព្រះវេស្សន្តរមានក្រឹត្យវិន័យយ៉ាងតឹងរ៉ឹង មិនទាក់ទងនឹងផ្លូវកាមគុណឡើយក្នុងពេលយប់ ទោះបីមានហេតុការណ៍ធំដុំបែបណាក៏ដោយ ។ លើសពីនេះទៀត ព្រះអង្គពុំមែនលះបង់តែទ្រព្យសម្បត្តិប៉ុណ្ណោះទេ ក្នុងមហាបរិច្ចាគ៥ ព្រះអង្គបានដាក់ទានបុត្រទាំងពីរឲ្យតាជូជក ដាក់ទានព្រះនាងមទ្រីឲ្យឥន្ទព្រាហ្មណ៍ ។ ខ្ពស់លើសពីនេះទៀត សូម្បីអវៈយវៈនិងជីវិតរបស់ព្រះអង្គ ក៏ព្រះអង្គបានតាំងព្រះទ័យលះរួចហើយ ។

មូលបញ្ហាធំក្នុងរឿងព្រះវេស្សន្តរនេះ ពុំមែនកសាងនេក្ខម្មៈបារមី គឺការចេញបួសទេ គឺមូលបញ្ហាស្ថិតនៅលើទានបារមី គឺការបំពេញទាន ។ ឯរឿងនេក្ខម្មបារមី គឺការចេញបួស គឺរឿងព្រះតេមិយកុមារវិញទេ ។

រឿងព្រះវេស្សន្តរដែលចេញទៅបួសជាតាបសឥសីនោះ គឺជាអនុបញ្ហា គឺបញ្ហារាយរង ជាមធ្យោបាយដោះស្រាយបញ្ហាដែលអ្នកស្រុកស្រីពិរាស្ត្របានបណ្ដេញព្រះអង្គចេញពីព្រះនគរ ។ ឆ្លៀតពេលគង់នៅភ្នំគីរីវង្កត ព្រះអង្គខំព្យាយមអប់រំព្រះទ័យរបស់ព្រះអង្គឲ្យស្អាតបរិសុទ្ធ ជាពិសេសអប់រំព្រះទ័យឲ្យលះបង់សេចក្ដីកំណាញ់ ដើម្បីបំពេញទានបារមីឲ្យខ្ពស់ឡើងថែមទៀត ។ ដូច្នេះឃើញថា សូម្បីគង់នៅក្នុងព្រៃភ្នំ ក៏ព្រះអង្គនៅតែជាប់ព្រះទ័យក្នុងការបំពេញទានជានិច្ច ។ ដោយឃើញថា ព្រះវេស្សន្តរជាក្សត្រមានធម៌សប្បុរស មានព្រះទ័យជាប់ជានិច្ចក្នុងការជួយសង្គ្រោះមនុស្ស ជាពិសេសពុំប្រឆាំងមតិរបស់រាស្ត្រ ទើបអ្នកស្រីពិរាស្ត្រសំរេចទូលព្រះបាទស្រីសញ្ជ័យ ឲ្យយាងព្រះវេស្សន្តរត្រឡប់មកនគរវិញ ព្រះអង្គនឹងបានបំពេញទានបារមីជាបន្តទៅទៀត ព្រះវេស្សន្តរក៏យល់ព្រមតាមការយាងនេះ ។ ដូច្នេះការត្រឡប់ទៅកាន់នគរសោយរាជ្យវិញនេះរបស់ព្រះអង្គ ពុំមែនយាងទៅដើម្បីជួយដោះស្រាយបញ្ហាសង្គមមនុស្ស ដែលកំពុងមានការអត់ឃ្លានជាធំ ។ តាមការបញ្ចប់រឿងព្រះវេស្សន្តរបានកាន់សីលបរិសុទ្ធ ហើយបានទូន្មាននាម៉ឺនសព្វមុខមន្ត្រី ព្រមទាំងប្រជារាស្ត្រឲ្យកាន់សេចក្ដីសុចរិត យុត្តិធម៌ ហើយព្រះអង្គបន្តការធ្វើអំណោយដល់អ្នកក្រីក្រលំបាកជាបន្តទៅទៀត ។

អ្នកដឹកនាំខ្មែរគ្រប់ជំនាន់ គួរទាញយកឧត្តមគតិនៃរឿងនេះ ហើយព្យាយាមដោះស្រាយបំបាត់ភាពក្រីក្រនៃពលរដ្ឋខ្មែរឲ្យបានឆាប់រហ័ស ។៚

*　　　　*

*